# សេចក្តីថ្លែងការណ៍រួម
# សង្គមស៊ីវិលថ្កោលទោសចំពោះការអនុម័តច្បាប់ចំនួនបីទាក់ទងនឹងកំណែទម្រង់ប្រព័ន្ធតុលាការ ដែលមានខ្លឹមសារចន្លោះប្រហោង និងអំពាវនាវជាថ្មីឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២១៤**

យើងខ្ញុំ ក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដូចមានរាយនាមខាងក្រោម សូមអំពាវនាវឲ្យព្រឹទ្ធសភាកម្ពុជាពន្យារការពិនិត្យសេចក្តីព្រាងច្បាប់ចំនួនបីទាក់ទិននឹង "កំណែទម្រង់" ប្រព័ន្ធតុលាការ ដែលរដ្ឋសភាបានអនុម័ត ហើយប្រសិនបើច្បាប់ទាំងនេះត្រូវបានអនុម័តដោយព្រឹទ្ធសភាទៀតនោះ អាចនឹងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់នីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

យើងខ្ញុំសូមអំពាវនាវជាថ្មីឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ និងទូលំទូលាយ ដើម្បីកែសម្រួលច្បាប់ទាំងនេះឲ្យស្របនឹងបទដ្ឋានអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") នឹងពង្រឹងអំណាចគ្រប់គ្រងរបស់ខ្លួនកាន់តែខ្លាំងឡើងលើចៅក្រម និងព្រះរាជអាជ្ញានៅក្នុងប្រទេស ប្រសិនបើសេចក្តីព្រាងច្បាប់ ដែលមានទម្រង់ដូចពេលចុងក្រោយនេះត្រូវបានអនុម័តឲ្យក្លាយទៅជាច្បាប់ ដែលនេះជាការគំរាមកំហែងធ្ងន់ធ្ងរមួយដល់នីតិរដ្ឋនៅកម្ពុជា។

កាលពីថ្ងៃទី២២ និងទី២៣ ខែឧសភា រដ្ឋសភាបានអនុម័តជាបន្តបន្ទាប់ដ៏ឆាប់រហ័សលើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ច្បាប់ទាំងនេះនឹងត្រូវបញ្ជូនបន្តទៀតទៅព្រឹទ្ធសភាដើម្បីពិនិត្យ ហើយបន្ទាប់មកទៀតត្រូវពិនិត្យដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញរបស់កម្ពុជា។

បច្ចុប្បន្ននេះ រដ្ឋសភាមានតែតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា ខណៈដែលគណបក្សប្រឆាំង គឺគណបក្សសង្គ្រោះជាតិ ធ្វើពហិកាចូលកាន់អាសនៈរបស់ខ្លួននៅសភាចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៣ ដោយចោទប្រកាន់ជុំវិញការបន្លំសន្លឹកឆ្នោត ដែលជាលទ្ធផលអាចឲ្យគណបក្សប្រជាជនកម្ពុជាមានលទ្ធភាពអនុម័តច្បាប់ទាំងនោះ ដោយពុំមានការជំទាស់។

ច្បាប់ទាក់ទងទៅនឹង 'កំណែទម្រង់' ប្រព័ន្ធតុលាការ ដែលបានស្នើឡើងទាំងនេះ រំពឹងថានឹងពង្រឹងដល់នីតិរដ្ឋ តាមរយៈការពង្រឹងនូវឯករាជ្យភាពរបស់តុលាការនៅកម្ពុជា ដែលយល់ឃើញពីដំបូងថា ជាផ្នែកនៃផែនការសកម្មភាពថ្នាក់ជាតិ ដើម្បីធ្វើឲ្យច្បាប់ជាតិមានលក្ខណៈស្របតាមកាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិរបស់ខ្លួន។

ផ្ទុយទៅវិញ ច្បាប់ដែលត្រូវបានអនុម័តទាំងនេះផ្តល់អំណាចកាន់តែទូលំទូលាយដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើចៅក្រម និងព្រះរាជអាជ្ញា ហេតុដូច្នេះនឹងធ្វើឲ្យប៉ះពាលដល់ឯករាជ្យភាព និងធ្វើឲ្យរដ្ឋាភិបាលអាចគ្រប់គ្រងតាមផ្លូវច្បាប់លើចៅក្រម និងព្រះរាជអាជ្ញា។

ការអនុម័តសេចក្តីព្រាងច្បាប់ទាំងនេះធ្វើឡើង បន្ទាប់ពីដំណាក់កាលតាក់តែងច្បាប់ដែលមានលក្ខណៈលាក់លៀមរួចមក។ តាំងពីដំបូង រដ្ឋាភិបាលបានបដិសេធការពិគ្រោះយោបល់ជាមួយសាធារណជន សង្គមស៊ីវិល និងដៃគូពាក់ព័ន្ធដទៃៗទៀត បានបដិសេធមិនផ្សព្វផ្សាយនូវសេចក្តីព្រាងច្បាប់ដើម ព្រមទាំងប្រានចោលការស្នើផ្តល់មតិយោបល់ និងការជួយផ្សេងៗ។

នៅដើមខែឧសភានេះ សង្គមស៊ីវិលបានអំពាវនាវឲ្យរដ្ឋសភាពន្យារការពិភាក្សាលើច្បាប់ទាំងនេះ ព្រមទាំងបានជំរុញឲ្យមានការពិភាក្សាទូលំទូលាយ និងជាសាធារណៈ។ ប៉ុន្តែ សេចក្តីអំពាវនាវនេះមិនត្រូវបានពិចារណានោះទេ។

សេចក្តីព្រាងច្បាប់ដែលបានតាក់តែងនេះ បំពានលើគោលការណ៍នៃការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការដែលចែងក្នុងមាត្រា ៥១ មាត្រា ១២៨ និង មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងបំពានលើច្បាប់ និងបទដ្ឋានអន្តរជាតិមួយចំនួន។ ជាពិសេស ផ្ទុយទៅនឹងមាត្រា ១៤ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលធានាអំពីសាលាជម្រះក្តីឯករាជ្យ និងឥតលម្អៀង ផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់តុលាការ សេចក្តីប្រកាសស៊ីងវី និងសេចក្តីថ្លែងការណ៍នៃគោលការណ៍ទីក្រុងប៉េកាំង។

មានការព្រួយបារម្ភជាខ្លាំងថា ច្បាប់ទាំងនេះប្រគល់អំណាចហួសហេតុដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសមាជិកនៃអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល គ្រប់គ្រងលើចៅក្រម និងព្រះរាជអាជ្ញា។

សេចក្តីប្រកាសស៊ីងវីស្តីពីឯករាជ្យភាពនៃតុលាការចែងថា តុលាការត្រូវតែឯករាជ្យពីអង្គនីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិ ហើយមានតែប្រធានតុលាការប៉ុណ្ណោះដែលមានអំណាចគ្រប់គ្រងកិច្ចការរដ្ឋបាលលើចៅក្រមបាន។ ទន្ទឹងនឹងនេះដែរ កថាខ័ណ្ឌទី ៣៥ នៃសេចក្តីថ្លែងការណ៍នៃគោលកាណ៍ទីក្រុងប៉េកាំង ដែលជាឯកសារមួយត្រូវបានអនុម័តដោយចៅក្រមនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិច ចែងយ៉ាងច្បាស់ថា មានតែប្រធានតុលាការប៉ុណ្ណោះដែលអាចបែងចែងសំណុំរឿងឲ្យចៅក្រមបាន។

ផ្ទុយនឹងសេចក្តីប្រកាសស៊ីងវី និងសេចក្តីថ្លែងការណ៍នៃគោលការណ៍ទីក្រុងប៉េកាំង សេចក្តីព្រាងច្បាប់ថ្មីទាំងនេះផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៖ គ្រប់គ្រង និងចាត់ចែងរាល់កិច្ចការរដ្ឋបាលរបស់តុលាការ និងព្រះរាជអាជ្ញា រួមទាំងរឿងថវិកា និងដំឡើងថ្នាក់ ឬផ្តល់ដំណែងឡើវិញ, ធ្វើជានាយឋានានុក្រមនៃអង្គការអយ្យការ និងអាចចេញអធិបញ្ញាទៅអយ្យការគ្រប់ជាន់ថ្នាក់, កំណត់ចំនួនសិស្សចៅក្រម និងព្រះរាជអាជ្ញា, ចូលរួមផ្តល់យោបល់ក្នុងការដំឡើងថ្នាក់របស់ចៅក្រម និងព្រះរាជអាជ្ញា, សម្រេចតាមការស្នើសុំរបស់មន្ត្រីរដ្ឋាភិបាល ដែលពុំទទួលបានការបណ្តុះបណ្តាលជាព្រះរាជអាជ្ញា ដើម្បីអាចក្លាយជាព្រះរាជអាជ្ញា, សម្រេចលើការស្នើសុំច្បាប់ឈប់សម្រាករបស់ចៅក្រម ឬព្រះរាជអាជ្ញា ដើម្បីប្រកបកិច្ចការឯកជន, តែងតាំងក្រុមអធិការកិច្ច ដើម្បីស៊ើបអង្កេតលើការរំលោភបំពានវិន័យរបស់តុលាការ, និងត្រួតពិនិត្យលើការរៀបចំសំណុំរឿងពាក់ព័ន្ធនឹងវិន័យ។

ការដាក់ស្ថាប័នតុលាការឲ្យស្ថិតនៅក្រោមអង្គនីតិប្រតិបត្តិត្រូវបានបង្ហាញឲ្យឃើញយ៉ាងជាក់ច្បាស់។ សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដំបូងឡើយ មានបទប្បញ្ញត្តិមួយចែងថា តុលាការ "នឹងមិនត្រូវស្ថិតនៅក្រោមស្ថាប័ននីតិប្បញ្ញត្តិ ឬ នីតិប្រតិបត្តិ ឬ គណបក្សនយោបាយណាមួយឡើយ"។ ប៉ុន្តែ បទប្បញ្ញត្តិនេះត្រូវបានលុបចោលវិញ មុនពេលរដ្ឋសភាអនុម័តច្បាប់ថ្មីទាំងនេះ។

ម្យ៉ាងវិញទៀត យោងតាមគោលការណ៍ទី ៨ នៃគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់តុលាការ ចៅក្រមមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដរាបណាចៅក្រមប្រព្រឹត្តខ្លួនក្នុងលក្ខណៈ ដែលរក្សាសេចក្តីថ្លៃថ្នូរនៃតួនាទីរបស់ខ្លួន និងឯករាជ្យភាពរបស់តុលាការ។

ជាការរំលោភបំពានលើគោលការណ៍មូលដ្ឋាននេះ មាត្រា ៥៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចែងថា ចៅក្រមត្រូវតែសុំការអនុញ្ញាតជាមុនពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់ទាក់ទងនឹងការងាររបស់ខ្លួន។

អាស្រ័យដូចនេះហើយ យើងខ្ញុំ ជាក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ស្នើឲ្យព្រឹទ្ធសភាពន្យារការត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ទាំងនេះ និងស្នើឲ្យមានការពិគ្រោះយោបល់ជាមួយសាធារណជន សង្គមស៊ីវិលនានា ដើម្បីធានាថា ច្បាប់ទាំងនេះអនុលោមតាមបទដ្ឋានអន្តរជាតិ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**


១) លោក សួន ប៊ុនស័ក្តិ លេខាប្រតិបត្តិរបស់ CHRAC តាមរយៈទូរសព្ទ +៨៥៥ (០) ៩២ ៣៤៤ ៣៥៧ ឬ តាមរយៈអ៊ីម៉ែល ៖ suonbunsak@yahoo.com

២) លោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក តាមរយៈទូរសព្ទលេខ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬ តាមរយៈអ៊ីម៉ែល ៖ duchpiseth@cchrcambodia.org

៣) លោក឴ ឃីងស្លី អែបត់ ទីប្រឹក្សាច្បាប់អន្តរជាតិរបស់ ICJ តាមរយៈទូរសព្ទ +៦៦ (០) ៩៤ ៤៧០ ១៣៤៥ ឬ តាមរយៈអ៊ីម៉ែល ៖ kingsley.abbott@icj.org


**សេចក្តីថ្លែងការណ៍នេះទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិដូចខាងក្រោម ៖**

១) គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
២) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
៣) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
៤) គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ)
៥) អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW)
៦) អង្គការលើកលែងទោសអន្តរជាតិ (AI)
៧) សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
៨) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
៩) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច